eTiQa

ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត អេទីកា

**អេទីកា ឡាយហ្វ៍ អ៊ិនស្ទួរេន (ខេមបូឌា) ម.ក**

**ជាន់ទី 8 អគារមេយប៉ែង** លេខ43 មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី3 ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ៖ **015 212321** អ៊ីម៉ែល៖ **life@etiqa.com.kh**
គេហទំព័រ៖ **www.etiqa.com.kh**





## 7 ជម្រើសនៃអត្ថប្រយោជន៍នៅពេលដល់កាលកំណត់នៃបណ្ណសន្យារ៉ាប់រង

លោកអ្នកអាចជ្រើសរើសអត្ថប្រយោជន៍សាច់ប្រាក់ ចាប់ពី 70% ដល់ 100% នៃបុព្វលាភធានារ៉ាប់រងសរុបដូចជា៖70% 75% 80% 85% 90% 95% និង 100%។

## ភាពបត់បែននៃការបង់បុព្វលាភធានារ៉ាប់រង និង ការធានាមានរយៈពេលវែង

ជម្រើសនៃរយៈពេលបង់បុព្វលាភធានារ៉ាប់រងចាប់ពី 5, 10, 15 ឆ្នាំ ឬរហូតដល់កាលកំណត់នៃបណ្ណសន្យារ៉ាប់រង និងជម្រើសការធានារយៈពេលវែងរហូតដល់ 25 ឆ្នាំ។





## បុព្វលាភធានារ៉ាប់រងមានតម្លៃសមរម្យ

ត្រឹមតែ $184 សម្រាប់ទឹកប្រាក់ធានារ៉ាប់រង $5,000 ជាមួយនឹងអត្ថប្រយោជន៍នៅពេលផុតកំណត់បណ្ណសន្យាធានារ៉ាប់រង 70% នៃបុព្វលាភធានារ៉ាប់រងសរុប ជាមួយការបង់បុព្វលាភធានារ៉ាប់រង 5ឆ្នាំ និង ការធានារយៈពេល 10 ឆ្នាំ ឬ តម្លៃនឹងកាន់តែទាប បើលោកអ្នកជ្រើសរើសការបង់បុព្វលាភធានារ៉ាប់រងរយៈពេលកាន់តែវែង

## អត្ថប្រយោជន៍ធានារ៉ាប់រង

ការធានាលើករណីមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ឬ **200% នៃទឹកប្រាក់ធានារ៉ាប់រង** ក្នុងករណីគ្រោះថ្នាក់ចៃដន្យ។



# ករណីមិនធានា

ទាំងនេះគឺជាករណីមិនធានាសំខាន់ៗ។ សម្រាប់ព័ត៌មានលម្អិត និងលក្ខខណ្ឌផ្សេងទៀត សូមយោងទៅតាមកិច្ចសន្យារ៉ាប់រងដែលបានផ្តល់ជូន។

**ក្នុងករណី ឬ ហេតុការណ៍កើតឡើងទោះដោយផ្ទាល់ ឬ មិនផ្ទាល់ក្តីដោយសារមូលហេតុណាមួយដូចខាងក្រោមនោះ មិនមានអត្ថប្រយោជន៍នៃទឹកប្រាក់ធានារ៉ាប់រងនឹងត្រូវផ្តល់ជូនឡើយ៖**

- ការប៉ុនប៉ងធ្វើអត្តឃាត ឬរងរបួសដោយខ្លួនឯង ទោះបីជាមានសតិល្អប្រក្រតី ឬមិនប្រក្រតីក្តី
- ការប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌ ដោយម្ចាស់បណ្ណសន្យារ៉ាប់រង អ្នកត្រូវបានធានារ៉ាប់រង និងអ្នកទទួលផល
- ផលវិបាកដែលបណ្តាលមកពីអ្នកត្រូវបានធានារ៉ាប់រង ស្ថិតក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬការប្រើប្រាស់គ្រឿងញៀន លើកលែងតែមានវេជ្ជបញ្ជាពីអ្នកអនុវត្តផ្នែកវេជ្ជសាស្ត្រដែលមានចុះបញ្ជីត្រឹមត្រូវ
- លទ្ធផលនៃសង្គ្រាម ទោះបានប្រកាស ឬមិនបានប្រកាស ការលុកលុយ សង្គ្រាមស៊ីវិល ការបះបោរ និងកុបកម្ម
- លទ្ធផលដែលបណ្តាលមកពីអ្នកត្រូវបានធានារ៉ាប់រងចូលរួមកីឡា ឬបណ្តុះបណ្តាល កីឡាគ្រោះថ្នាក់ ឬការប្រកួតដែលមានគ្រោះថ្នាក់ ឬគ្រោះថ្នាក់ណាមួយ ឬជិះ ឬបើកបរក្នុងទម្រង់នៃការប្រណាំង ឬការប្រកួតណាមួយ
- បណ្តាលមកពីការហោះហើរ ឬទម្រង់ណាមួយនៃការហោះហើរលើអាកាស ក្រៅពីការបង់ថ្លៃជាអ្នកធ្វើដំណើររបស់ក្រុមហ៊ុនអាកាសចរណ៍ ដែលត្រូវបានគេទទួលស្គាល់ការហោះហើរទៀងទាត់ និងតាមពេលវេលាកំណត់ ឬ
- ការឆ្លងវីរុសបង្កដោយមេរោគហ៊ីវ (HIV) ជំងឺអេដស៍ (AIDS) ឬជំងឺណាមួយដែលកើតឡើងដោយសារជំងឺអេដស៍(AIDS)។